**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាចារ្យប្រុស ធឿន ជាអ្នកថ្លែងព្រះបន្ទូលជាផ្លូវការ នៅបឹងទំពុន**
**ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧**

***ព្រះបន្ទូលស្ថិតនៅក្នុងចំណោមយើង***

អត្ថបទទី១៖ អស ៤០,១-៥.៩-១១
អត្ថបទទី២៖ ២សល ៣,៨-១៤
ដំណឹងល្អ៖ មក ១,១-៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជាមេរៀនមួយសម្រាប់យើង គឺសម្រាប់ព្រះជាម្ចាស់មួយថ្ងៃហាក់បីដូចជាមួយពាន់ឆ្នាំ មួយពាន់ឆ្នាំហាក់បីដូចជាមួយថ្ងៃ។ ដូច្នេះ ឲ្យយើងចេះជ្រើសរើស អ្វីដែលយើងត្រូវការធ្វើឲ្យយើងការពារថែរក្សាពេលកំណត់ អ្វីដែលប្រញាប់ឲ្យយើងធ្វើឆាប់ៗ អ្វីដែលយើងយកពេលដើម្បីចូលជ្រៅ គឺត្រូវការយកពេលវេលាដូចព្រះជាម្ចាស់។ ថ្ងៃនេះ ព្រះសហាគមន៍ឲ្យយើងសម្លឹងមើលលោកយ៉ូហានបាទីស្ត។

នៅយប់បុណ្យព្រះយេស៊ូប្រសូត យើងអានអត្ថបទគម្ពីរមួយដែលស្តីពីរឿង ព្រះយេស៊ូប្រសូត ជាមួយនាងម៉ារី លោកយ៉ូសែប ជាមួយគ្រូគង្វាល។ ប៉ុន្តែពេលថ្ងៃទី២៥ព្រឹក យើងចូលវិហារម្តងទៀត ហើយនៅពេលនោះយើងស្តាប់គម្ពីរមួយទៀត ជាអត្ថបទនេះចេញពីលោកយ៉ូហាន។ យើងអានព្រះបន្ទូលមួយពិសេស គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស ព្រះបន្ទូលហ្នឹង ស្ថិតនៅក្នុងចំណោមយើង។ ដើម្បីអនុវត្តន៍អ្វីដែលលោកយ៉ូហានបាទីស្ត បានយកចិត្តទុកដាក់ប្រកាសអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកយ៉ូហានបាទីស្ត បានថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលព្រះយេស៊ូប្រសូត យើងមើលឃើញ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស គឺព្រះយេស៊ូតែម្តង ដែលយាងមកក្នុងចំណោមយើង។ បេសកកម្មរបស់យើងជាគ្រីស្តបរិស័ទ បេសកកម្មមុនគេបង្អស់ដែលយើងត្រូវតែអនុវត្តន៍ជាប្រចាំ គឺសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ សម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង **តើយើងត្រូវការធ្វើអ្វីខ្លះ?** សម្តេចប៉ាបយ៉ូហានទី១៦ បានរំឭកដល់យើងសម្តែងធម៌មេត្តាករុណា ដែលសំខាន់និងជាអាទិភាព **គឺប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់**។ ដូច្នេះ មុននឹងជួយដល់អ្នកក្រីក្រ មុននឹងជួយដល់អ្នកជំងឺ មុននឹងធ្វើអ្វីផ្សេងៗទៀត យើងត្រូវតែប្រកាសដំណឹងល្អ។ ធម៌មេត្តាករុណារបស់

ព្រះជាម្ចាស់ គឺប្រកាសដំណឹងល្អអំពីព្រះយេស៊ូគ្រីស្ទដែលកំពុងយាងមក និងធ្វើដំណើរជាមួយយើងពីមួយថ្ងៃទៅមួយថ្ងៃ។

ហេតុនេះ សម្រាប់បងប្រុស ធឿន ដែលទទួលបេសកកម្មដ៏ពិសេសប្រកាសដំណឹងល្អ ជាបេសកកម្មរបស់លោកឪពុក របស់លោកអភិបាល របស់គ្រីស្តបរិស័ទទាំងអស់។ មិនមែនតែអានអត្ថបទគម្ពីរនៅក្នុងអភិបូជា ប៉ុន្តែដើម្បីប្រកាសដំណឹងល្អតាមរបៀបដែលយើងរស់នៅ។ នេះជារបៀបយើងជាគ្រីស្តបរិស័ទ ដែលសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គឺប្រកាសដំណឹងល្អតាមរបៀបដែលយើងរស់នៅ។ ព្រះបន្ទូលនេះ ជាព្រះបន្ទូលមួយដែលយើងត្រូវការស្តាប់ៗ។ អត្ថបទទីមួយ "**ចូរឡើងទៅលើភ្នំខ្ពស់ ក្រុងយេរូសាឡឹមជាអ្នកនាំដំណឹងល្អអើយ! ចូរស្រែកឲ្យអស់ទំហឹងឲ្យគេឮដល់ កុំខ្លាចអ្វីឡើយ! ចូរប្រាប់ទៅក្រុងទាំងប៉ុន្មាននៅស្រុកយូដាថា មើល៍ហ្ន៎ ព្រះរបស់អ្នករាល់គ្នា! មើល៍ហ្ន៎ ព្រះជាម្ចាស់ដែលយាងមកប្រកបដោយឫទ្ធានុភាព ព្រះអង្គយាងមកប្រកបដោយឫទ្ធិបារមី ដើម្បីគ្រងរាជ្យ**" នេះជារបៀបដែលយើងត្រូវការប្រកាសដំណឹងល្អ។ ដំណឹងល្អមិនមែនជាអាថ៌កំបាំងមួយដែលយើងទុកសម្រាប់យើង ដំណឹងល្អមិនមែនជារឿងសំងាត់ដែលយើងទុកយ៉ាងស្ងាត់ៗនៅក្នុងដួងចិត្តរបស់យើង។ ថ្ងៃនេះ ព្រះសហគមន៍បានអញ្ជើញយើងឲ្យឡើងទៅលើភ្នំ ដើម្បីប្រកាសដំណឹងល្អឲ្យអស់ពីកម្លាំង ដើម្បីឲ្យគេឮឲ្យគេស្តាប់។

នៅពេលខ្ញុំជានិស្សិតទេវវិទ្យាល័យ គេបង្រៀនអំពីរបៀបអានគម្ពីរ និងរបៀបនិយាយនៅតាមមេក្រូ។ ពេលយើងនិយាយ កុំនិយាយទៅមនុស្សដែលនៅជិតៗ សូមនិយាយដល់មនុស្សដែលអង្គុយនៅចុងក្រោយ។ ហេតុនេះហើយ កម្លាំងរបស់យើងចេញពេញដើម្បីឲ្យគេស្តាប់ឮ។ អ្វីដែលសំខាន់ គឺជីវិតរបស់យើងទៅជាសំឡេងរបស់ព្រះជាម្ចាស់ឲ្យមនុស្សស្តាប់ឮ។ មានន័យថា ជីវិតរបស់យើងទៅជាសាក្សីយ៉ាងជាក់ស្តែង យើងមិនខ្លាចអ្វីទេ យើងឡើងលើភ្នំដើម្បីប្រកាសអស់ពីទំហឹង នូវព្រះបន្ទូលដែលយើងបានទទួល ព្រះបន្ទូលដែលជាទ្រព្យសម្បត្តិរបស់យើង។ កន្លែងណាដែលមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ កន្លែងហ្នឹងមានទ្រព្យសម្បត្តិនៃជីវិតរបស់យើង។

ប៉ុន្តែ លោកយ៉ូហានបាទីស្ត បានរើសកន្លែងមួយដើម្បីប្រកាសដំណឹងល្អ គាត់មិនទៅក្រុងយេរូសាឡឹម គាត់មិនទៅក្នុងភូមិដែលមានមនុស្សយ៉ាងច្រើន គាត់មិនទៅក្នុងធម្ម

សាលាដូចព្រះយេស៊ូ ដែលជួបជុំគ្នាដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែគាត់ទៅវាលរហោស្ថាន។ វាលរហោស្ថាននៅក្នុងដួងចិត្តរបស់យើង ដួងចិត្តរបស់យើងដែលស្ងួត ដួងចិត្តរបស់មនុស្សដែលពីមួយថ្ងៃទៅមួយថ្ងៃរវីរវល់តែរកស៊ី មានលុយឬអត់ រវីរវល់ពីរឿងតូចតាច តែរឿងសំខាន់លែងរវីរវល់ជាមួយព្រះជាម្ចាស់។ លែងនឹកនាដើម្បីកោតសរសើរព្រះជាម្ចាស់ លែងបង្កើតទំនាក់ទំនងជ្រៅនៅក្នុងដួងចិត្តរបស់យើង នៅក្នុងផ្លូវវិញ្ញាណរបស់យើង ដើម្បីចិញ្ចឹមដោយទឹកយ៉ាងពិសេស គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះ វាលរហោស្ថាន អត់ត្រូវការទៅដល់វាលស្រែដែលអត់មានមនុស្ស ប៉ុន្តែនៅកន្លែងដែលយើងនៅសព្វថ្ងៃដែលមានមនុស្សយ៉ាងច្រើន ដែលអត់ដែលគិតសោះពីជីវិតខាងផ្លូវវិញ្ញាណ អំពីព្រះបន្ទូលដែលណែនាំឲ្យមានសេចក្តីសង្ឃឹម អំពីព្រះបន្ទូលដែលជាពន្លឺតូចមួយ ដើម្បីឲ្យជីវិតរបស់យើងទៅមុខ។ យើងដឹងថា ព្រះបន្ទូលរបស់ព្រះយេស៊ូជាត្រីវិស័យដើម្បីបើកផ្លូវ ដើម្បីបើកផ្លូវ ដូចហោរាចារ្យ គេបានមើលផ្កាយ និងគេបានដើរតាមផ្កាយនេះ ហើយគេបានទៅដល់កន្លែងដើម្បីគោរពព្រះយេស៊ូ។ ឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅជាផ្កាយហ្នឹង! ដើម្បីបង្ហាញផ្លូវ យើងទទួលបេសកកម្មមួយយ៉ាងពិសេស។

សម្រាប់ជីវិតរបស់យើង ដែលជាអ្នកដែលថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងត្រូវការប្រកាសពិតមែនអស់ពីទំហឹង ដើម្បីឲ្យគេស្តាប់ឮ ពិតមែនយើងត្រូវការធ្វើជាពន្លឺត្រីវិស័យមួយយ៉ាងពិសេស ឲ្យគេមើលឃើញផ្លូវដើម្បីធ្វើដំណើរ។ ប៉ុន្តែ សំខាន់មុនគេបង្អស់ ឲ្យយើងយកព្រះបន្ទូលចូលក្នុងដួងចិត្ត ដើម្បីចិញ្ចឹមជីវិតរបស់យើង ដើម្បីឲ្យព្រះបន្ទូលនេះទៅជាតែមួយជាមួយជីវិតរបស់យើង។ ដើម្បីឲ្យព្រះបន្ទូលនេះ ពីមួយថ្ងៃទៅមួយថ្ងៃ យើងស្តាប់ដើម្បីកែប្រែចិត្តគំនិត។ របៀបរបស់ព្រះជាម្ចាស់ "**ព្រះអង្គសម្តែងព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូន ព្រោះទ្រង់បានសព្វព្រះហឫទ័យឲ្យនរណាម្នាក់ត្រូវវិនាសទេ គឺទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សលោកគ្រប់ៗរូបកែប្រែចិត្តគំនិត**"។ ដើម្បីកែប្រែចិត្តគំនិត ព្រះជាម្ចាស់មានព្រះហឫទ័យអត់ធ្មត់ មួយថ្ងៃហាក់បីដូចជាមួយពាន់ថ្ងៃ មួយពាន់ថ្ងៃហាក់បីដូចជាមួយថ្ងៃ។ យើងត្រូវតែយកពេល ដើម្បីឲ្យព្រះបន្ទូលចូលទៅក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យព្រះបន្ទូលនេះកែប្រែចិត្តគំនិតរបស់យើងបន្តិចម្តងៗ ឲ្យយើងមានសមត្ថភាពថ្លែងព្រះបន្ទូលតាមរបៀបដែលយើងរស់នៅ តាមរបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ។

រដូវរង់ចាំ គឺពេលវេលាដើម្បីរៀបចំចិត្តគំនិតទទួលស្វាគមន៍ព្រះយេស៊ូ ដែលកំពុងយាងមក។ ព្រះយេស៊ូជាព្រះបន្ទូល ព្រះបន្ទូលបានចាប់កំណើតជាមនុស្ស និងព្រះបន្ទូលហ្នឹងស្ថិតនៅក្នុងចំណោមយើង។ នេះជាការអស្ចារ្យ ដែលយើងនឹងគោរពនៅយប់ព្រះយេស៊ូប្រសូត។ ពិតមែនព្រះបន្ទូលបានចាប់កំណើតជាមនុស្ស និងព្រះបន្ទូលស្ថិតនៅក្នុងចំណោមយើង ឲ្យយើងយកពេលដើម្បីកែប្រែចិត្តគំនិតថែមទៀត ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចិញ្ចឹមជីវិតយើង និងដើម្បីបំភ្លឺជីវិតរបស់បងប្អូនឯទៀតៗ។ យើងអធិដ្ឋានដោយសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានជ្រើសរើសយើងធ្វើជាបុត្រធីតារបស់ព្រះអង្គ។ យើងអធិដ្ឋាន សូមអរព្រះគុណព្រះជាម្ចាស់ដែលបានជ្រើសរើសបងប្រុស ធឿន ធ្វើជាកូនសិស្សរបស់លោកអភិបាល និងថ្ងៃនេះដើម្បីទៅជាព្យាការីម្យ៉ាងដោយថ្លែងព្រះគម្ពីរនៅក្នុងជីវិតរបស់គាត់។ អាម៉ែន៕